# «A9» អ្នកថែទាំម៉ាស៊ីនយានយន្ត ដ៏ប្រសើរ ជួយម៉ាស៊ីនដំណើរការបានកាន់តែឆ្ងាយ

## ◆ ប្រើ «A9» ទោះម៉ាស៊ីនយានយន្តអស់ប្រេង ក៏នៅតែដំណើរការបាន





លោក ឈរ ប៊ុនសាម លើកបង្ហាញផលិតផល «A9» និង ចាក់បញ្ចូលទៅក្នុងប្រេងម៉ាស៊ីនរថយន្តបង្ហាញពីប្រសិទ្ធភាព

**ភ្នំពេញ៖** ផលិតផលប្រកបដោយបច្ចេកវិទ្យាទំនើប របស់ប្រទេសបារាំង ក្នុងការថែទាំម៉ាស៊ីនយានយន្តគ្រប់ប្រភេទ ឈ្មោះថា «A9» មានវត្តមាននៅលើទីផ្សារកម្ពុជាហើយ។ «A9» ជាផលិតផល ដែលយកទៅចាក់បញ្ចូលក្នុងប្រេងម៉ាស៊ីនយានយន្តគ្រប់ ប្រភេទដើម្បីជួយកាត់កាត់បន្ថយកំដៅឬចំហេះក្នុងម៉ាស៊ីនយានយន្ត និងការបំពុលបរិយាកាស ជាពិសេសជួយឲ្យយានយន្តដំណើរការ បានកាន់តែឆ្ងាយរាប់ម៉ឺនគីឡូម៉ែត្រ ទោះអស់ប្រេងម៉ាស៊ីន នៅតែអាចបន្តដំណើរបាន មិនបង្កផលប៉ះពាល់ដល់ម៉ាស៊ីនឡើយ។

ជាមួយការដាក់បង្ហាញផលិតផលដែលមានបច្ចេកវិទ្យាទំនើប សម្រាប់ថែទាំយានយន្តកាលពីព្រឹកថ្ងៃ ទី០៣ ខែកញ្ញា លោក ឈរ ប៊ុនសាម ប្រធានក្រុមហ៊ុនឈរ ប៊ុនសាម អ៊ិនវេសមិន បានមានប្រសាសន៍ថា ផលិតផលរបស់បារាំងឈ្មោះ «A9» គឺជាផលិតផលថ្មី ហើយអាចប្រើប្រាស់ បានគ្រប់រថយន្តទាំងអស់ម៉ាស៊ីនម៉ូតូ ក៏ប្រើបានដែរ។ «A9» គ្រាន់តែចាញ់បញ្ចូលក្នុងធុងប្រេងម៉ាស៊ីនរថយន្ត។សមត្ថភាពរបស់«A9» មានគុណភាពខ្ពស់ ក្នុងកាកាត់បន្ថយការបំពុលបរិស្ថានដូចជាផ្សែងខ្មៅ ដែលចេញពីបំពង់ស៊ីមាំងរថយន្ត ធ្វើឲ្យម៉ាស៊ីនរថយន្តលែងសឹករេចរិល ជួយកាត់បន្ថយដំណក់ជាតិប្រេង និងទឹក ដែលដក់ក្នុងម៉ាស៊ីនងាយឲ្យម៉ាស៊ីនមានច្រេះ ធ្វើឲ្យម៉ាស៊ីមានកម្លាំងខ្លាំង និងម៉ាស៊ីនស៊ីប្រេងតិច។

លោក ឈរ ប៊ុនសាម បញ្ជាក់ថា ប្រសិនបើរថយន្តណា ដែលបានប្រើផលិតផល «A9» ហើយនៅពេលបើកបរអស់ប្រេងម៉ាស៊ូតជាយថាហេតុណាមួយនោះ មិនអាចធ្វើឲ្យម៉ាស៊ីប្រេះបែកនោះទេ លើសពីនេះវាអាចដំណើរការបានរហូតដល់ ៣ ម៉ឺនគីឡូម៉ែត្រទៀត។ អ្វីដែលពិសេសនៅពេលប្រើប្រាស់វា អាចបង្ហូរប្រេងម៉ាស៊ីនចេញ ក៏អាចប្រើប្រាស់បានចម្ងាយ ៥ពាន់គីឡូម៉ែត្រ (នៅបារាំង)។ចំពោះប្រភេទម៉ាស៊ីន ដែលមិនប្រើផលិផល «A9» អាចបើកបរមិនលើស ២គីឡូម៉ែត្រ។ ផលិតផលត្រូវផលិតឡើងដោយជនជាតិបារាំង និងត្រូវបានចែកចាយលក់ប្រើប្រាស់នៅប្រទេសចំនួន៨ក្នុងនោះ: មាន ប្រទេសបារាំង កាណាដា, អូស្ត្រាលី, ស្វីស, ស្វរវៀត ...និងប្រទេសនៅតំបន់អាហ្វិក ។

លោកបញ្ជាក់ថា «ចំពោះរយៈពេល នៃការប្រើផលិតផលម៉ាក «A9» យើងត្រូវប្រើចម្ងាយផ្លូវ ៣ម៉ឺនគីឡូម៉ែត្រ ទើបប្តូរប្រេងម្តង។ ប៉ុន្តែអ្នកប្រើរថយន្ត ត្រូវតែថែទាំរថយន្តតាមលក្ខណៈធម្មតា។ ធម្មតារថយន្តដែលមិនប្រើផលិតផល A9 បានចម្ងាយតែ